ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ....២៣៣១.....អពដ

GENERAL DEPARTMENT OF TAXATION

# សេចក្ដីប្រកាសព័ត៌មាន

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងដល់គ្រប់ ក្រសួង ស្ថាប័ន អង្គភាព និងសាធារណជនទាំងអស់មេត្តាជ្រាបថា ថ្មីៗនេះ មានការផ្សព្វផ្សាយតាមទូរទស្សន៍ CNC ពីព័ត៌មានមួយ បំផ្លើសខុសពីការពិត ដោយគ្មានមូលដ្ឋានច្បាស់លាស់ត្រឹមត្រូវ បានចោទប្រកាន់ថាមានការឃុបឃិតគ្នាប្រព្រឹត្តនូវអំពើពុករលួយនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ និងបានបង្ហាញនូវអង្គការលេខមានរូបថត។

អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការបដិសេធទាំងស្រុងចំពោះការផ្សព្វផ្សាយព័ត៌មាននេះ ដែលជាព័ត៌មានភូតកុហក បំផ្លើសការពិត មានចេតនាមួលបង្កាច់ និងបង្ខូចកិត្តិយស ពីព្រោះព័ត៌មាន និងអង្គការលេខមានរូបថតនេះ គឺត្រូវបានរៀបចំដោយបុគ្គលវិកលចរិតម្នាក់ ដែលជាអតីតមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ២០១៣។ បុគ្គលនេះបានរៀបចំ បានផ្សព្វផ្សាយ និងកំពុងព្យាយាមបន្តផ្សព្វផ្សាយនូវព័ត៌មាន និងរូបភាពជាច្រើនដែលមានលក្ខណៈ ភូតកុហកបំផ្លើសការពិត មានចេតនាមួលបង្កាច់ និងបង្ខូចកិត្តិយស។ បុគ្គលនោះក៏បានបង្កនូវសកម្មភាពមិនប្រក្រតីជាច្រើននៅក្នុងអគ្គនាយកដ្ឋានពន្ធដារ និងនៅខាងក្រៅ ដូចជារំលោភយកដីគេនៅខេត្តកណ្ដាល និងខេត្តកោះកុង និងបន្លំខ្លួនជាឧត្តមសេនីយ៍យោធាជាដើម។ ជាងនេះទៅទៀត អគ្គស្នងការនគរបាលជាតិ បានចាប់ខ្លួនយកទៅសួរចម្លើយក្នុងករណីប្រើប្រាស់អាវុធខុសច្បាប់ និងភ្ជង់សម្លុត គំរាមកំហែងដល់មន្ត្រីក្នុងអគ្គនាយកដ្ឋានពន្ធដារ។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានលុបឈ្មោះបុគ្គលនោះចេញពីបញ្ជីមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាំងពី ខែធ្នូ ឆ្នាំ ២០១៣ មកម្ល៉េះ។ ម្យ៉ាងទៀត អគ្គនាយកដ្ឋានពន្ធដារសូមស្នើគ្រប់បណ្ដាញសារព័ត៌មានទាំងអស់ បញ្ឈប់ការផ្សាយព័ត៌មានទាំងនេះ ដោយសារការចុះផ្សាយព័ត៌មានដោយគ្មានការទទួលខុសត្រូវ និងគ្មានមូលដ្ឋាន ព្រមទាំងគ្មានបានសួរមកអគ្គនាយកដ្ឋានពន្ធដារឱ្យឆ្លើយតបទៅវិញ ដែលប្រការនេះបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយសរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារដែលជាស្ថាប័នរដ្ឋ ក៏ដូចជាសេចក្ដីថ្លៃថ្នូររបស់សារព័ត៌មានដទៃទៀត ដែលប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងវិជ្ជាជីវៈសារព័ត៌មាន។

ជាទីបញ្ចប់ អគ្គនាយកដ្ឋានពន្ធដារសូមអំពាវនាវដល់សារព័ត៌មានទាំងអស់ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន ក្នុងការផ្សព្វផ្សាយនូវព័ត៌មានដែលមានប្រភពពិតប្រាកដ ត្រឹមត្រូវ ដោយវិធីសុចរិត គតិយុត្តិធម៌ ដើម្បីរួមចំណែកលើកស្ទួយវិជ្ជាជីវៈសារព័ត៌មាន សេចក្ដីថ្លៃថ្នូរ និងជាកញ្ចក់សច្ចធម៌ សម្រាប់ជាឧត្តមប្រយោជន៍ដល់ជាតិមាតុភូមិ និងប្រជាពលរដ្ឋកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ២០១៥

**អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន ពន្ធដារ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh